ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សាររំលែកមរណៈទុក្ខ

**ជូនចំពោះ**

**លោក មុំ វីរៈ នាយកខុទ្ទកាល័យ និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងខ្លាំងដោយបានទទួលដំណឹងថា **ឧបាសក មុំ សំអុល** ដែលត្រូវជាឪពុកបង្កើត **លោក មុំ វីរៈ** នាយកខុទ្ទកាល័យបានទទួលមរណភាពនៅថ្ងៃចន្ទ២រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៦:២០ នាទីរសៀល ក្នុងជន្មាយុ ៧១ ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានចិត្តដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវមរណៈទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកកប្បការជូនចំពោះ **ឧបាសក មុំ សំអុល** ដែលបានធ្វើមរណកាលលាចាកលោក លាចាកពីបុត្រធីតា និងក្រុមញាតិគ្រួសារជាទីស្រលាញ់។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឧបាសក មុំ សំអុល** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកនាយកខុទ្ទកាល័យ និងក្រុមគ្រួសារ** ទទួលនូវការរំលែកទុកដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃអង្គារ ០៣រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងមុខងារសាធារណៈ

ហ៊ុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh